សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

លេខ៖ ០៨២/២០២០

**ជម្រាបជូន**

- **នាយកប្រតិបត្តិ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ** (LICADHO)
- **នាយកប្រតិបត្តិ សម្ព័ន្ធសហជីពកម្ពុជា** (CATU)
- **នាយកប្រតិបត្តិ មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស** (CENTRAL)
- **នាយកប្រតិបត្តិ សមាគមធាងត្នោត** (Sahmakum Teang Tnaut)

**កម្មវត្ថុ ៖** ១. សំណើកែតម្រូវរាល់របាយកាណ៍មិនពិតប្រាកដ ដែលចេញផ្សាយដោយស្ថាប័ន **លោក លោកស្រី** ពី "ការនាំឱ្យមានចំណាកស្រុក" ចេញផ្សាយនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដោយ LICADHO

២. ត្រួតពិនិត្យឡើងវិញ និងធ្វើការកែសម្រួលទៅតាមករណីចាំបាច់ នូវរបាយកាណ៍ "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ" ចេញផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ ដោយ LICADHO និងសមាគមធាងត្នោត និងរបាយកាណ៍ស្តីពី "ធ្វើការងាររហូតដំពាក់បំណុលវ័ណ្ឌក" ចេញផ្សាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដោយ LICADHO, CATU និង CENTRAL។

**យោង ៖**
- អត្ថបទស្តីពី "ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ" ចេញផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩ ដោយ LICADHO និងសមាគមធាងត្នោត
- អត្ថបទស្តីពី "ការនាំឱ្យមានចំណាកស្រុក" ចេញផ្សាយនៅថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដោយ LICADHO
- អត្ថបទស្តីពី "ធ្វើការងាររហូតដំពាក់បំណុលវ័ណ្ឌក" ចេញផ្សាយនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ដោយ LICADHO, CATU និង CENTRAL
- របាយការណ៍លម្អិត អំពីភាពមិនប្រក្រតីនៃការសិក្សារបស់LICADHO ចេញផ្សាយនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២០ ដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ តាងនាមឱ្យសមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា យើងខ្ញុំសូមជម្រាបជូន **លោក លោកស្រី** ជ្រាបថា ក្នុងកាលៈទេសៈការរីករាលដាលជាសកលនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានជ្រោមជ្រែង និងយកចិត្តទុកដាក់បំផុតក្នុង ការទប់ស្កាត់នូវផលប៉ះពាល់ផ្សេងៗ ដោយដាក់ចេញនូវវិធានការ អនុគ្រោះជាច្រើន ដើម្បីគាំពារលើគ្រប់វិស័យ នានាដែលរងផលប៉ះពាល់ធ្ងន់ធ្ងរ ជាពិសេសគឺការគាំពារប្រជាពលរដ្ឋ។

ស្ថិតក្នុងគ្រាដ៏លំបាកដែលយើងគប្បីសហប្រតិបត្តិការគ្នាជាមួយអ្នកពាក់ព័ន្ធ ដើម្បីទប់ស្កាត់ជំងឺឆ្លងកូវីដ១៩ អង្គការរបស់លោក លោកស្រីចេញផ្សាយនូវរបាយកាណ៍មិនពិតជាបន្តបន្ទាប់ ដូចជា៖ "**ការធ្វើឱ្យខូចខាតទ្រព្យដាក់បញ្ចាំ៖ ការបាត់បង់ដីធ្លី និងការរំលោភបំពានក្នុងវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា**" ចេញផ្សាយដោយ LICADHO និង សមាគមធាងត្នោត "**ការនាំឱ្យមានចំណាកស្រុក៖ បទពិសោធន៍នៃភូមិមួយអំពីបំណុលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការចំណាកស្រុកឆ្លងដែន**" ចេញផ្សាយដោយ LICADHO និងរបាយកាណ៍ "**ធ្វើការងាររហូតជំពាក់បំណុលវ័ណ្ឌក៖ ភាពជំពាក់បំណុលច្រើនលើសលុបក្នុងវិស័យកាត់ដេរនៅប្រទេសកម្ពុជា**" ចេញផ្សាយដោយ CATU, CENTRAL និង LICADHO។

សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា មើលឃើញថា របាយកាណ៍ទាំងនោះបានចេញផ្សាយដោយគ្មានមូលដ្ឋានវិទ្យាសាស្ត្រ ខ្វះតម្លាភាព ជាពិសេសមិនដែលបាន សាកសួរឬពិភាក្សាជាមួយស្ថាប័នជំនាញពាក់ព័ន្ធ។ អត្ថបទដែលគ្មានមូលដ្ឋានច្បាស់លាស់មិនគ្រប់ជ្រុងជ្រោយនេះទៀតសោត បានផ្តល់ឱកាសឱ្យជនខិលខូចមួយចំនួន យកទៅផ្សព្វផ្សាយបន្ត ក្នុងចេតនាញុះញង់ បង្កចលាចលដល់សង្គមជាតិ នាំឱ្យប៉ះពាល់កិត្តិយស សេចក្តីថ្លៃថ្នូរ របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងសន្តិសុខជាតិ។

សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា សូមភ្ជាប់ជូននូវសេចក្តីថ្លែងការណ៍ឆ្លើយតបនិងរបាយការណ៍លំអិតពាក់ព័ន្ធ ដែលសមាគមបានរកឃើញ ដែលមានដូចខាងក្រោម៖

១. សេចក្តីថ្លែងការណ៍ ស្តីពីភាពមិនប្រក្រតីនៃរបាយការណ៍របស់អង្គការលីកាដូ ចេញផ្សាយថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ២០២០ ដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
(https://cma-network.org/information-center/events-announcement/detail/cma-statement-on-irregularities-of-licadho-study-on-migration-and-mfis/) និងរបាយកាណ៍លម្អិត(https://bit.ly/3eR6egQ)

២. សេចក្តីថ្លែងការណ៍រួម របស់សមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ចេញផ្សាយថ្ងៃទី ២៨ ខែមេសា ឆ្នាំ២០២០ ឆ្លើយតបនឹងរបាយកាណ៍ "ការនាំឱ្យមានចំណាកស្រុក"
(https://www.abc.org.kh/news/joint-statement-abc-cma-response-licadho-report)

៣. សេចក្តីថ្លែងការណ៍ ឆ្លើយតបទៅនឹងរបាយការណ៍ "ធ្វើការងាររហូតដល់ជំពាក់បំណុលវណ្ឌ ក" ចេញនៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២០ ចេញដោយសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
(https://cma-network.org/km/information-center/events-announcement/detail/សេចក្តីថ្លែងការណ៍-ឆ្លើយ/)

យើងខ្ញុំសូមបញ្ជាក់ផងដែរ រាល់ការផ្តល់ឥណទានរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុលោមតាមច្បាប់ជាតិ បទប្បញ្ញត្តិពាក់ព័ន្ធជាមូលដ្ឋាន និងគោលប្រតិបត្តិអន្តរជាតិ។ ក្នុងនោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយចំនួន ទទួលបានវិញ្ញាបនបត្រកំណារពារអតិថិជន ពីស្ថាប័នវាយតម្លៃអន្តរជាតិ។ គ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជា តែងតែចាត់ទុកអតិថិជនជាដៃគូយូរអង្វែង ហើយយើងជឿជាក់ថា ជោគជ័យរបស់អតិថិជនទើបជាជោគជ័យពិតប្រាកដ របស់គ្រឹះស្ថានហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ សមាគមយើងខ្ញុំ សូមស្នើឱ្យអង្គការសង្គមស៊ីវិលខាងលើ គប្បីធ្វើការកែតម្រូវចំពោះអត្ថបទដែលជាការសន្មត់ផ្ទាល់ខ្លួន និងសរសេរផ្ទុយពីការពិតនេះ ឱ្យបានឆាប់រហ័សបំផុត។

សូម **លោក លោកស្រី** ទទួលនូវសេចក្តីរាប់អានអំពីយើងខ្ញុំ៕

ថ្ងៃពុធ ១០រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០

| | |
|---|---|
| **សមាគមធនាគារនៅកម្ពុជា** | **សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា** |
| ASSOCIATION OF BANKS IN CAMBODIA | CAMBODIA MICROFINANCE ASSOCIATION |
| **បណ្ឌិត អ៊ិន ចាន់នី** | **គា ប៊ុណ្ណារ៉ា** |